**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ ១២២/២៣ អអរ**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះវិហារ"

រសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះវិហារ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម គីម រិទ្ធី អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តព្រះវិហារ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តព្រះវិហារ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តព្រះវិហារ បែងចែកចេញជា ក្រុង១ ស្រុក៧ ឃុំ៤៩ សង្កាត់២ និងភូមិចំនួន ២៣២ ដែលមានប្រជាពលរដ្ឋរស់នៅចំនួន ២៦០.៨៦១នាក់ ស្មើនឹង ៦៤.៨៤៦គ្រួសារ។ សេដ្ឋកិច្ចខេត្ត មានទំហំប្រមាណ ២៣៣លានដុល្លាអាមេរិក ស្មើនឹង ០,៩% នៃសេដ្ឋកិច្ចជាតិ មានការកើនឡើង ៥% បើធៀបនឹងឆ្នាំ២០២១ ហើយចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ១.០៧០ ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គរបស់រាជរដ្ឋាភិបាល ដែលបានរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយអត្រាភាពក្រីក្រ ដោយសម្រេចបាននូវការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ ចំនួន ១៤.៩០៦គ្រួសារ ចំណាយថវិកា ៧៥.០៩១.៥២០.០០០រៀល ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១៧.៣៥២ករណី អស់ទឹកប្រាក់ ៨៧៥.០៤០.០០០រៀល និងគ្រួសារដែលងាយរងហានិភ័យដោយសម្ពាធអតិផរណាចំនួន ៥.៩១២គ្រួសារ ចំណាយថវិកា ៨០៩.៩៤៧.៦០០រៀល។
- **វិស័យកសិកម្ម៖** ជាវិស័យសំខាន់ ដែលទ្រទ្រង់សេដ្ឋកិច្ចក្នុងខេត្តទាំងមូល ដែលប្រជាពលរដ្ឋប្រមាណជាង ៨០% ប្រកបរបរកសិកម្មនេះ។ ក្នុងឆ្នាំ២០២២ ការអនុវត្តស្រូវវស្សាបានចំនួន ៩៩,១២០ហិកតា ទទួលបានផលសរុប ២៨៣.៧៤៣តោន ក្រៅពីនោះមានដំណាំរួមផ្សំ ដំណាំកសិ-ឧស្សាហកម្ម និងដំណាំហូបផ្លែមួយចំនួនទៀត ដែលអនុវត្តបាន ៦៣.៤៣៤ហិកតា។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត ក៏បានចងក្រងជាសហគមន៍កសិកម្មមានចំនួន ៤៣សហគមន៍ ដែលផ្តោតទៅលើការធ្វើឥណទានកសិកម្មខ្នាតតូច ផ្គត់ផ្គង់សម្ភារៈកសិកម្ម ធ្វើរបរទីផ្សារ និងបានចុះកិច្ចសន្យាទិញ-លក់ផលកសិកម្មផងដែរ។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈ៖** ដោយមានការចូលរួមពីកងកម្លាំងគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ល្អប្រសើរ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ទទួលបានលទ្ធផលល្អ បទល្មើសនានាមានការថយចុះ។ ជាមួយគ្នានេះ ការផ្តល់សេវាសាធារណៈ ក៏មានលក្ខណៈងាយស្រួល ឆាប់រហ័ស និងទាន់ពេលវេលា ទទួលបានការសាទរពីប្រជាពលរដ្ឋ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ ដោយក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ អង្គភាពច្រកចេញ-ចូលតែមួយ បានផ្តល់សេវាជូនសាធារណជនសរុបចំនួន ៣៧.៦៣៧សេវា ទទួលបានចំណូល ៥.០៥៥.៦៦១.០០០រៀល។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** រដ្ឋបាលខេត្ត បានបន្តការស្តារហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតទៅលើការកសាង ជួសជុល ថែទាំទាំងផ្លូវជាតិ ផ្លូវខេត្ត ផ្លូវជនបទឱ្យមានគុណភាពខ្ពស់ សំដៅតភ្ជាប់បណ្តាញផ្លូវពីទីរួមខេត្ត ទៅកាន់បណ្តាស្រុក និងឃុំនានាទូទាំងខេត្ត ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ជំរុញកំណើនសេដ្ឋកិច្ចជាតិ។

- **វិស័យទេសចរណ៍៖** ជាខេត្តដែលសម្បូរទៅដោយប្រាង្គប្រាសាទបុរាណ និងព្រៃឈើ ដែលសុទ្ធសឹងតែជាសក្តានុពលទាក់ទាញនូវភ្ញៀវទេសចរ។ ជាក់ស្តែង ខេត្តទទួលបានភ្ញៀវទេសចរសរុប ២.២១៥.៨៥៦នាក់ ក្នុងនោះភ្ញៀវជាតិ ២.០៥៦.១០៥នាក់។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានធ្វើការអប់រំ បណ្តុះបណ្តាលប្រជាពលរដ្ឋទាក់ទងនឹងវិស័យទេសចរណ៍ ទាំងជំនាញគេហកិច្ច មគ្គុទេសក៍ទេសចរណ៍ ជំនាញអាហារ និងភេសជ្ជៈជាដើម ក្នុងន័យផ្តល់នូវជំនាញច្បាស់លាស់ជូនប្រជាពលរដ្ឋ ក្នុងការផ្តល់សេវាកម្មជូនភ្ញៀវទេសចរប្រកបដោយគុណភាពខ្ពស់។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តព្រះវិហារ បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដែលរួមមាន៖

- ខិតខំអនុវត្តកម្មវិធីនយោបាយនានា ជាពិសេសគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែទទួលបាននូវជោគជ័យបន្ថែម
- បន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ សំដៅលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍលើគ្រប់វិស័យ
- បន្តពង្រឹង និងអភិវឌ្ឍន៍ធនធានមនុស្ស គុណភាពអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បន្តពង្រឹង និងជំរុញការអនុវត្តកសិកម្មតាមកិច្ចសន្យាចំពោះផលិតផលសរីរាង្គ និងជំរុញប្រជាកសិករឱ្យខិតខំបង្កើនផល ពង្រឹងគុណភាពកសិផល ស្របនឹងតម្រូវការទីផ្សារ
- បន្តខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រៀបចំពង្រឹងរមណីយដ្ឋានទេសចរណ៍ ព្រមទាំងខិតខំប្រែក្លាយទៅជាខេត្តសរីរាង្គ៕Den

ថ្ងៃព្រហស្បតិ៍ ២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣